ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

គណៈកម្មាធិការលទ្ធកម្ម

លេខ : 1063 PEAC.អក

រាជធានីភ្នំពេញ,ថ្ងៃទី 02 ខែសីហា ឆ្នាំ 2016

# សេចក្តីជូនដំណឹង

## ស្តីពី

**ការផ្គត់ផ្គង់ 24kV Circuit Breaker និងបរិក្ខាចាំបាច់សម្រាប់ផ្លាស់ប្តូរ ចំនួន 10 មុខ ជូននាយកដ្ឋានបញ្ជូនអគ្គិសនី**

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថាអគ្គិសនីកម្ពុជា នឹងដាក់អោយដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់ 24kV Circuit Breaker និងបរិក្ខាចាំបាច់សម្រាប់ផ្លាស់ប្តូរ ចំនួន 10 មុខ ជូននាយកដ្ឋានបញ្ជូនអគ្គិសនី ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញ ដើម្បីចូលរួមដេញថ្លៃ និង មានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជា ដែលមានអាសយដ្ឋាន ៖ អាគារលេខ ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញចាប់ពីថ្ងៃទី 05 ខែ សីហា ឆ្នាំ 2016 តទៅ រៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទងលេខ ៖ 023 67 66 007 និង Website : www.edc.com.kh ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង 14:00 ថ្ងៃទី 06 ខែកញ្ញា ឆ្នាំ 2016 ។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង 16:00 ថ្ងៃទី 06 ខែកញ្ញា ឆ្នាំ 2016 ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ចម្លងជូន ៖

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ